**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ០៣១ ន ..... សហវ.ប្រក

# ប្រកាស
## ស្តីពី
## វិធានការផ្នែកពន្ធដារដើម្បីកាត់បន្ថយផលប៉ះពាល់
## នៃបញ្ហាប្រឈមលើសហគ្រាសឧស្សាហកម្មផ្នែកវាយនភណ្ឌកាត់ដេរ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងវិសោធនកម្មជាបន្តបន្ទាប់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ០៩៨ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ស្តីពីពន្ធលើប្រាក់ចំណូល
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

### ប្រការ១.. គោលបំណង

ប្រកាសនេះ មានគោលបំណងដាក់ចេញនូវយន្តការផ្នែកពន្ធដារដើម្បីកាត់បន្ថយផលប៉ះពាល់នៃបញ្ហាប្រឈមលើសហគ្រាសឧស្សាហកម្មផ្នែកវាយនភណ្ឌកាត់ដេរ។

### ប្រការ២.. គោលដៅ

ប្រកាសនេះ មានគោលដៅកំណត់នូវវិធានការពន្ធដារ ក្នុងការផ្តល់នូវការអនុគ្រោះពន្ធលើប្រាក់ចំណូល ចំពោះសហគ្រាសវាយនភណ្ឌ ផលិតសម្លៀកបំពាក់ ផលិតស្បែកជើង ផលិតកាបូបយួរនិងកាបូបដៃ និងផលិតមួក ដែលរងផលប៉ះពាល់បណ្តាលមកពីការព្យួរប្រព័ន្ធអនុគ្រោះពន្ធ (EBA)។

### ប្រការ៣.. វិសាលភាព

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះសហគ្រាសវាយនភណ្ឌ ផលិតសម្លៀកបំពាក់ ផលិតស្បែកជើង ផលិតកាបូបយួរនិងកាបូបដៃ និងផលិតមួក នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ប្រការ៤.. វិធានកំណត់កម្រិតនៃផលប៉ះពាល់ជាក់ស្តែង

កម្រិតនៃផលប៉ះពាល់ជាក់ស្តែងសម្រាប់វាយតម្លៃ ដើម្បីអនុគ្រោះពន្ធលើប្រាក់ចំណូល ត្រូវកំណត់តាមរូបមន្តដូចខាងក្រោម÷

$$\text{កម្រិតនៃផលប៉ះពាល់ជាក់ស្តែង} = \frac{\text{ទំហំនៃការនាំចេញដែលរងផលប៉ះពាល់}}{\text{ទំហំនៃការនាំចេញសរុប}} \times ១០០$$

### ប្រការ៥.. ការអនុគ្រោះពន្ធលើប្រាក់ចំណូល

សហគ្រាសវាយនភណ្ឌ ផលិតសម្លៀកបំពាក់ ផលិតស្បែកជើង ផលិតកាបូបយួរនិងកាបូបដៃ និងផលិតមួក ត្រូវទទួលបានការអនុគ្រោះពន្ធលើប្រាក់ចំណូលសម្រាប់ឆ្នាំជាប់ពន្ធ ២០២០ ដោយផ្អែកលើកម្រិតនៃផលប៉ះពាល់ដូចខាងក្រោម÷

១- លើកលែងពន្ធលើប្រាក់ចំណូលរយៈពេល ៦ ខែ សម្រាប់រោងចក្រសហគ្រាសដែលរងផលប៉ះពាល់កម្រិតពី ២០% ទៅ ៣៩% ដោយលើកលែងពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំចំនួន ៥០% នៃប្រាក់ពន្ធត្រូវបង់សរុប។

២- លើកលែងពន្ធលើប្រាក់ចំណូលរយៈពេល ១ ឆ្នាំ សម្រាប់រោងចក្រសហគ្រាសដែលរងផលប៉ះពាល់កម្រិតពី ៤០% ទៅ ១០០% ដោយលើកលែងការបង់ពន្ធលើប្រាក់ចំណូល ១០០% នៃប្រាក់ពន្ធត្រូវបង់សរុប។

### ប្រការ៦.. លក្ខខណ្ឌដើម្បីទទួលបានការលើកលែងពន្ធលើប្រាក់ចំណូល

ដើម្បីទទួលបានការលើកលែងពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងប្រការ៥ នៃប្រកាសនេះ សហគ្រាសវាយនភណ្ឌ ផលិតសម្លៀកបំពាក់ ផលិតស្បែកជើង ផលិតកាបូបយួរនិងកាបូបដៃ និងផលិតមួក ត្រូវដាក់ជូនរដ្ឋបាលសារពើពន្ធនូវឯកសារបញ្ជាក់អំពីទំហំផលប៉ះពាល់ជាក់ស្តែងពីការព្យួរប្រព័ន្ធអនុគ្រោះពន្ធ (EBA) ក្នុងអំឡុងពេលប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។

**ប្រការ៧.- ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក និងអគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- សភាពាណិជ្ជកម្មកម្ពុជា
- សាលារាជធានី-ខេត្ត
- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ